# គម្ពីរទ្រៀង-មិញយ៉ាំង

## Le plan secret des Yuons

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី១ មេសា ២០០៦

នៅក្នុងចំណោមមនុស្សមួយចំនួនតូចនៅជួរមុខរដ្ឋាភិបាលលន់-នល់ ដែលបានងើបឡើងប្រឆាំងនឹងយួនឈ្លានពាន ហើយដែលបានបណ្តាលឲ្យកើតមានព្រឹត្តិការណ៍ទម្លាក់ស្តេចសីហនុ នៃថ្ងៃ១៨មីនា១៩៧០, គឺមានរូបខ្ញុំម្នាក់ដែរ ។ នៅកាលៈទេសៈបច្ចុប្បន្ន, ក្នុងចំណោមអ្នកទម្លាក់ស្តេចទាំងអស់នេះ គឺនៅសល់តែរូបខ្ញុំម្នាក់គត់ដែលនៅរស់ ហើយដែលបានសរសេរអំពីព្រឹត្តិការណ៍នេះឡើងវិញ ។

ក្នុងករណីនៃការរំឭកព្រឹត្តិការណ៍ចាស់ ដ៏សំខាន់ជាងគេបំផុតក្នុងជីវិតខ្ញុំ (ការទម្លាក់ស្តេចសីហនុ)... ខ្ញុំបានចំណាយពេលវេលាអស់៨ឆ្នាំ (ពីឆ្នាំ១៩៩០-១៩៩៨) ដើម្បីធ្វើការស្រាវជ្រាវនិងសរសេរសៀវភៅមួយជាភាសាបារាំង មានកម្រាស់៣៥០ទំព័រ ហើយដែលមានចំណងជើងថា ៖ Cambodge - Le Chemin de l'Apocalypse («កម្ពុជា - មាគ៌ាឆ្ពោះទៅរកមហាអន្តរាយ») ។ ហេតុអ្វីបានជាខ្ញុំសរសេរសៀវភៅនេះជាភាសាបារាំង ? ពីព្រោះកាលខ្ញុំរស់នៅក្នុងប្រទេសបារាំងអស់ចំនួន១០ឆ្នាំ ខ្ញុំធ្លាប់មានឋានៈជាអ្នកនិពន្ធភាសាបារាំង... ព្រមទាំងធ្លាប់បោះពុម្ពសៀវភៅបារាំងនៅទីក្រុងប៉ារីសរួចទៅហើយ... ម៉្យាងវិញទៀត ខ្ញុំមានជំនឿថា សរសេរជាភាសាបារាំងនឹងអនុញ្ញាតឲ្យសៀវភៅរបស់ខ្ញុំ ជ្រួតជ្រាបដល់មតិអន្តរជាតិ ។

ខ្ញុំបានសិក្សា «ចិត្តសាស្ត្រនិងទស្សនវិជ្ជា»នៅទីក្រុងភ្នំពេញ... និង«សង្គមសាស្ត្រនយោបាយ» (Hautes Etudes en Sciences Sociales) នៅទីក្រុងប៉ារីស ។ គឺវិជ្ជាទាំងពីរនេះហើយ ដែលអនុញ្ញាតឲ្យខ្ញុំរៀបរាប់អំពីព្រឹត្តិការណ៍ «១៨មីនា១៩៧០»ឡើងវិញ ដោយត្រឹមត្រូវនិងដោយសុក្រិត្យភាព (ដោយសច្ចៈយុត្តិធម៌) ជាពិសេស គឺបានអនុញ្ញាតឲ្យខ្ញុំរកឃើញ «គំរោងសម្ងាត់របស់ជនជាតិយួន ដើម្បីប្រល័យពូជសាសន៍ខ្មែរ» ពោលគឺ«គម្ពីររបស់ទ្រៀង-មិញយ៉ាំង» ។ ក្នុងប្រការសំរេចជោគជ័យនេះ, ខ្ញុំបានប្រឹងប្រែង មិនភូតភរខ្លួនឯងតាំងពីដំបូងទី (ភរភូតអ្នកដទៃមិនមែនជារឿងសំខាន់នោះទេ... ប៉ុន្តែភរភូតខ្លួនឯងនឹងនាំទៅរកសេចក្តីស្លាប់ !!) ពោលគឺខ្ញុំមិនដែលបានទុកខ្លួនឯងជាវិរបុរស, (ក្នុងករណីដែលថា បន្ទាប់ពីព្រឹត្តិការណ៍១៨មីនា១៩៧០, ប្រទេសកម្ពុជាដែលធ្លាប់តែសុខសប្បាយ បានធ្លាក់ទៅជាចំណីនៃ

ភ្លើងសង្គ្រាមមួយដ៏មហាខ្លោចផ្សារ)... ហើយខ្ញុំក៏មិនដែលបានចាត់ទុកខ្លួនឯងជាជនក្បត់ផងដែរ (ក្នុងករណីដែលថា ពួកយើង ពួកលន់-នល់បានងើបឡើងប្រឆាំងនឹងយួនឈ្លានពាន... ពុំមែនងើបឡើង ដើម្បីទម្លាក់ស្ដេចសីហនុនោះទេ) ។

នៅពេលចាប់ផ្ដើមសរសេរសៀវភៅនេះឡើង «មាគ៌ាឆ្ពោះទៅរកមហាអន្តរាយ», ខ្ញុំបានលើកយកចម្ងល់មួយដ៏ធំធេង ដែលចោទជាប្រស្នាក្រាស់ឃ្មឹកចាក់ភ្លែកមិនយល់... យកមកធ្វើដំណោះស្រាយ ៖ «ហេតុអ្វីបានជាសម្ដេចសីហនុ លើកតែងតាំងឧត្ដមសេនិយលន់-នល់ ជានាយករដ្ឋាភិបាលស្រោចស្រង់ជាតិ នៅក្នុងខែសីហា ១៩៦៩... រួចហើយក៏តាំងចោទលោកថា ជាភ្នាក់ងាររបស់សេអ៊ីអា ? ហេតុអ្វីបានជាសម្ដេចសីហនុ បានបញ្ជាឲ្យលោកឧត្ដមសេនិយលន់-នល់ បង្កើតមហាបាតុកម្មដេញយួនឈ្លានពាន នៅថ្ងៃ១១មីនា១៩៧០ រួចហើយក៏តាំងចោទលោកថា ជា«ជនក្បត់លក់ខ្លួនឲ្យចក្រពត្តិអាមេរិក ដើម្បីប្រាក់ដុល្លារ» ? ។

នៅទីបំផុត (នៅក្នុងឆ្នាំ១៩៩៨) ខ្ញុំក៏បានរកឃើញថា ស្ដេចសីហនុគ្រាន់តែជាទីងមោងឥតវិញ្ញាណ (Un agent inconcient) របស់វៀតណាមកុម្មុយនិស្ត ស្ដេចមួយអង្គដែលបានពោលថា ៖ «ខ្ញុំជាមនុស្សឆ្កួត... តែជាមនុស្សឆ្កួតប្រកបដោយបញ្ញាញាណ» (មនុស្សឆ្កួតដែលមានបញ្ញា មានតែនៅសហរដ្ឋអាមេរិកនេះទេ... គឺពួកដេកស៊ីប្រាក់ខែឆ្កួត) ។ មិនត្រឹមតែប៉ុណ្ណោះ សម្ដេចបានពោលបន្ថែមដូច្នេះទៀតថា ៖ «ដៃឆ្វេងរបស់ខ្ញុំ មិនដឹងថាដៃស្ដាំបានធ្វើអ្វីទេ» ៖ តាមសេចក្ដីពិតគឺអីចឹងមែន, ដៃឆ្វេងរបស់សម្ដេច បានបោយហៅពួកយៀកកុង ឲ្យមកតាំងនៅក្នុងទឹកដីកម្ពុជា...ចំណែកដៃស្ដាំរបស់ទ្រង់ បោយហៅលោក Kissinger ឲ្យមកទម្លាក់គ្រាប់បែក, ស្ដេចអង្គនេះពិតជាតុកត្តាបញ្ចូលរូបរបស់យួន គឺឥតវិញ្ញាណស្មារតីពីខ្លួនឯងទេ, ពោលគឺធ្វើអ្វីៗតាមតែខ្សែញាក់របស់វៀតណាម ក្នុងគោលបំណងឲ្យប្រជាជាតិខ្មែរ វិនាសសាបសូន្យតែប៉ុណ្ណោះ ។

ក្នុងប្រការបញ្ចប់សៀវភៅ «មាគ៌ាឆ្ពោះទៅរកមហាអន្តរាយ» ក្នុងឆ្នាំ១៩៩៨ ខ្ញុំបានសរសេរលិខិតមួយច្បាប់ ទៅលោកឪពុកធម៌របស់ខ្ញុំនៅប្រទេសបារាំង, លោក Philippe Héduy, អ្នកនិពន្ធបារាំងម្នាក់ដែលបានណែនាំខ្ញុំ ឲ្យបោះពុម្ពសៀវភៅប្រលោមលោក ៖ L'Anarchiste («ជនអនាធិបតេយ្យ») នៅ Editions de la Table Ronde ៖

«ឡុងប៊ីច, ថ្ងៃទី១១ មេសា ១៩៩៨

«ស្ងួស្ដីពុកធម៌

ខ្ញុំបានបោះបង់កិច្ចការនិពន្ធនៃសៀវភៅរំឭកព្រឹត្តិការណ៍អស់មួយរយៈពេលសិន... ពីព្រោះដោយហេតុថា ខ្ញុំមិនមានសមត្ថភាពរកមើលឃើញ នូវពន្លឺរស្មី សូម្បីតែបន្តិចបន្តួច ដែលអាចណែនាំរូបខ្ញុំឲ្យចេញផុតពីរូងភ្នំដ៏ខ្មៅងងិត ។ រួចហើយខ្ញុំក៏បានចាប់ផ្ដើមបន្តកិច្ចការស្រាវជ្រាវឡើងវិញ នៅពេលមុននេះថ្មីៗ... ហើយស្រាប់

តែក្នុងមួយរំពេជនោះ ខ្ញុំបានដឹងថា ការប្រឹងប្រែងរបស់ខ្ញុំទាំងប៉ុន្មាន ត្រូវបានទទួល
នូវតុំរង្វាន់ជោគជ័យដ៏ជាទីគាប់ចិត្ត ។ បន្ទាប់ពីបានប្រឹងប្រែងស្វែងរកយ៉ាងអស់ពីក
ម្លាំងកាយនិងចិត្ត ដោយពុំបានទទួលលទ្ធផលអ្វីទាំងអស់... ខ្ញុំក៏បែរជារកឃើញយ៉ា
ងធូរល្ហុយទៅវិញ ដោយគ្មានបានបញ្ចេញកម្លាំងអ្វីសោះ ពោលដោយប្រការទ្រង់
ញាណ (ស្មានទៅវាត្រូវប្រហែលគ្នានឹងការត្រាស់ដឹង) ។ នៅទីបំផុត ខ្ញុំក៏បានរៀបចំ
កសាងឡើងវិញ ដោយសារជំនួយនៃកម្រងអនុស្សាវរីយ៍ផ្ទាល់ខ្លួន នូវគ្រឿងគ្រៅ
ខ្សែខ្មៅមួយម្តងៗនៃប្រស្នាទាំងមូល ដែលលាក់បង្កប់នៅពីក្រោយថ្ងៃ១៨មីនា១៩
៧០ ។ ជាពិសេសខ្ញុំបានបញ្ចប់សៀវភៅមួយ ដែលមានកម្រាស់៣៥០ទំព័រ, ប្រកប
ដោយវិភាគសមស្រប, និងរឹងមាំដូចថ្មបេតុង, ពីព្រោះមានបង្អែកទៅលើទង្វើពិត
ប្រាកដ ដែលមានថ្ងៃខែត្រឹមត្រង់ទៀងទាត់ ។ សំរេចសំរួចទៅ ខ្ញុំមានមោទនភាព
ក្រៃពេក ដោយបានបញ្ចេញ«ស្នាដៃសម្ងាត់និងផ្ទាល់ខ្លួន»នេះ... ដោយបានរកឃើ-
ញអាថ៌កំបាំងនៃ «វិរភាពរបស់ខ្លួនឯង» (ដែលខ្ញុំមិនដែលចង់បានទាល់តែសោះ)...
ហើយពេលនេះ ខ្ញុំក៏ដឹងផងដែរ ថាខ្ញុំមានសមត្ថភាពអាចផ្តល់យុត្តិធម៌ ទៅដល់ជន
ជាតិខ្មែររាប់លាននាក់ ដែលបានស្លាប់ទៅនៅក្នុងភក់ជ្រាំ ដោយឥតបានទទួលពិធី
គោរពបូជាអ្វីទាំងអស់ ហើយមិនបានទាំងដឹងថា មកពីបុព្វហេតុអ្វីផង ។ ហើយចំ-
ណែកខ្លួនខ្ញុំផ្ទាល់ ដែលត្រូវស្លាប់ទៅវិញនៅក្នុងថ្ងៃណាមួយ... គឺច្បាស់ជាមិនមែន
ស្លាប់ទៅវិញ យ៉ាងភ្លឹភ្លើល្ងីល្ងើ ដោយចាញ់ប្រាជ្ញាគេនោះឡើយ... ដោយទៅថើបដៃ
ពួកក្រុមជនដែលបានពិឃាតរូបយើង (ខ្មែរយើង) ទាំងអស់គ្នានោះឡើយ ។

«កូនសោរសំរាប់បើកទ្វារអាថ៌កំបាំងនៃសោកនាដកម្មរបស់ខ្មែរ គឺបិតនៅត្រង់
ទំនាក់ទំនងរវាង «រដ្ឋប្រហារនៃថ្ងៃ១៨មីនា១៩៧០» ដែលគេយល់ថា ជាទង្វើរបស់
ឧត្តមសេនិយលន់-នល់ ក្នុងករណីដែលថា រដ្ឋប្រហារនេះបានបណ្តាលឲ្យស្តេច
សីហនុ រមៀលធ្លាក់ពីមុខតំណែង ហើយនិងការពិឃាតរង្គាល ទៅលើពួកយួនកា
តូលិក និងពួកយួនសេរី... ដែលគេយល់ថា ជាស្នាដៃរបស់ឧត្តមសេនិយលន់-ន
ល់ដូចគ្នា (ដោយហេតុថា ទង្វើទាំងពីរនេះបានលេចឡើងក្នុងពេលដំណាលគ្នា) ។

«ប៉ុន្តែទង្វើទាំងពីរនេះ គ្រាន់តែការវាយរូបភាពបញ្ចូលគ្នាតែប៉ុណ្ណោះ, គឺជាការ
បង្កើត «គ្លីសេ» ប្រសិទ្ធិគ្នាសំរាប់បញ្ឆោតនិងថ្លិនភ្នែក ។ យោងតាមបទពិសោធន៍រប
ស់ខ្ញុំផ្ទាល់ ដែលបានទៅផ្ទះលោកលន់-នល់ សឹងតែរាល់ថ្ងៃកាលពីសម័យនោះ
(សម័យទម្លាក់សម្តេច) ខ្ញុំបានលាតត្រដាងបង្ហាញថា រដ្ឋប្រហារនេះជារដ្ឋប្រហារក្លែ
ងក្លាយ ពីព្រោះរឿងកំប្លុកកំប្លែងដ៏សែនអពមង្គលខាងលើនេះ បានត្រូវទាញខ្សែពី
ចម្ងាយដោយសម្តេចសីហនុផ្ទាល់ ។ ស្តេចវង្វេងជាតិនេះ បានរៀបចំ «ការដួលរលំ
ខ្លួនឯង» ដើម្បីទាក់ទាញជនជាតិខ្មែរទាំងអស់ ឲ្យធ្លាក់ចូលក្នុងសំណាញ់មរណៈរប
ស់ផាំ-យ៉ាំងដុង រដ្ឋមន្ត្រីទី១វៀតណាមខាងជើង ។ អ្វីៗដែលជនជាតិខ្មែរមិនដែល
បានដឹងទាល់តែសោះ សូម្បីតែរហូតមកដល់សព្វថ្ងៃនេះ គឺសីហនុគ្រាន់តែមានល

ក្ខណៈជាអាយ៉ងអចិន្ត្រៃយ៍របស់ទីក្រុងហាណូយតែប៉ុណ្ណោះ ។
«ដូចគ្នានឹងករណីដែលបញ្ជាក់ថា រដ្ឋប្រហារនេះជាទង្វើដ៏ព្រហើនកោងកាច ពី
សំណាក់ក្រុងហាណូយ, ការសម្លាប់យ៉ាងរង្គាល ដ៏សែនអមនុស្សធម៌ ដែលប្រព្រឹ
ត្តទៅលើពួកឃួនសេរីនិងពួកកាតូលិកចំនួន៥,០០០នាក់ ក៏ជាស្នាដៃឧក្រិដ្ឋកម្មរប-
ស់លោកផាំ-យ៉ាំងដុងតែមួយដដែល ក្នុងប្រការទម្លាក់ទោសកំហុស ទៅលើរបប
សាធារណរដ្ឋរបស់លោកលន់-នល់ ដែលទើបនឹងកើតឡើង ព្រមទាំងច្បាមជ្រមុ
ជប្រទេសកម្ពុជា ទៅក្នុងភ្នក់ភ្លើងសង្គ្រាម និងទៅក្នុងថ្លុកឈាម ឲ្យមានលក្ខណៈ
ថយក្រោយ ព្រៃផ្សៃប្រហែលគ្នាមុនពេលបារាំងមកដល់ កាលពីសតវត្សកន្លងទៅ
។ ដោយសារតែខ្ញុំធ្លាប់មានបទពិសោធន៍ ក្នុងការរស់នៅជាមួយពួកយោធារបស់
លោកលន់-នល់ កាលពីសម័យ១៨មីនា១៩៧០, ហើយដោយសារខ្ញុំមានភស្តុតាង
គ្រប់គ្រាន់ មិនអនុញ្ញាតឲ្យជនណាប្រកែកបាន... ខ្ញុំក៏បានលាតត្រដាងបង្ហាញថា រដ្ឋា
ភិបាលលន់-នល់ពុំមានមធ្យោបាយនិងពេលវេលាគ្រប់គ្រាន់ ដើម្បីប្រព្រឹត្តឃាត-
កម្មដ៏គួរឲ្យខ្ពើមរអើមទាំងនេះទេ ។ ពួកកងទ័ពលន់-នល់ ជាពួកកាន់លទ្ធិពុទ្ធនិយម
ហើយបានរស់លាយឡំនឹងប្រជាជនស៊ីវិល... ពួកអ្នកទាំងនេះពុំបាននឹកឃើញបង្កើ
តក្រុមកុម្មង់ដូឃាតករ ឲ្យដូចពួកខាងយៀកកុងនោះឡើយ (ពួកក្រុមពិឃាតរង្គាល
គេត្រូវមានពេលបង្ហាត់បង្រៀនជាយូរអង្វែងឆ្នាំ ដូចគេបង្ហាត់ឆ្កែកាចអីចឹងឯង) ។ ពួ
កកងយោធាខ្មែរមានចំនួនតែសាមសិបពាន់នាក់ប៉ុណ្ណោះ ប្រដាប់ដោយគ្រឿងអាវុធ
ស្គមស្គាំង ដើម្បីប្រយុទ្ធតទល់នឹងពួកយៀកកុង២០០,០០០នាក់ ដែលប្រដាប់ដោ-
យគ្រឿងអាវុធទំនើប តាំងពីក្បាលដល់ចុងជើង ។
«បន្ទាប់ពីបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ថោកទាបនេះរួចហើយ ពួកកុម្មុយនិស្តវៀត-
ណាម ដោយមានសម្តេចសីហនុជាមេឃោសនារបស់ពួកគេជាផ្លូវការ បានរៀបចំ
យុទ្ធនាការបំពុលមតិអន្តរជាតិ ដោយទម្លាក់ទោសកំហុសនៃសង្គ្រាមរបស់ខ្មែរ ទៅ
លើឧត្តមសេនិយលន់-នល់ និងពួកអាមេរិកាំង ។ ទាំងនេះ គឺជាករណីបង្វែងដាន
តែប៉ុណ្ណោះ ។ មើលចុះសៀវភៅរបស់សម្តេចសីហនុ ៖ «សង្គ្រាមរបស់ខ្ញុំតទល់នឹ
ងសេអ៊ីអា» គឺជាវណ្ណកម្មដ៏ឆ្នើមរបស់ពួកកុម្មុយនិស្ត (ដោយមានសហការជាមួយ
នឹងអ្នកនិពន្ធកុម្មុយនិស្ត Wilfred Burchett ដែលមាននិន្នាការបំរើមនោគមវិជ្ជារបស់
ទីក្រុងហាណូយ) ។ ដូច្នេះទៅ ជនជាតិខ្មែរដែលជាអ្នករងគ្រោះសោះ ក៏បានប្រែក្លា
យទៅជាពួកឃាតករ ចំណែកពួកឃាតករកុម្មុយនិស្តក៏បានប្រែក្លាយទៅជាពួកជន
រងគ្រោះទៅវិញ ។ គឺជាសីលធម៌បះក្រឡាប់ក្បាលចុះក្រោមជើងឡើងលើ ។ ពិភព
លោកទាំងមូលក៏ចាប់ផ្តើមមានការស្អប់ខ្ពើមជនជាតិខ្មែរ ដ៏កាចសាហាវយង់ឃ្នងនិ
ងឆ្កួតលីលា ដែលមានជម្ងឺវិកលចរិតនៃការប្រព្រឹត្តអំពើឥតផលប្រយោជន៍»...។ ពួ
កបញ្ញាជនឆ្វេងនិយមអន្តរជាតិក៏បានស្រែកជេរប្រទេចផ្តាសាររបបលន់-នល់យ៉ាង
ទ្រហឹងអ៊ឹងកង ។ ក៏ប៉ុន្តែការពិឃាតរង្គាលទៅលើពួកជនវៀតណាមសេរី ដែលប្រ

ឆាំងនឹងកុម្មុយនិស្ត ក៏បានធ្វើឲ្យមានការរំជើបរំជួលយ៉ាងខ្លាំង នៅក្នុងចំណោមពួកស្តាំនិយមផងដែរ ។ ម្ល៉ោះហើយការវាយប្រហារឈ្លានពានពីសំណាក់ហាណូយទៅលើរបបសាធារណរដ្ឋនៅទីក្រុងភ្នំពេញ គឺវាបែបជាសមស្របជាមួយនឹងគោលបំណងនៃព្រះជាម្ចាស់ទៅហើយ ។

«ដូច្នេះទៅ ដោយគ្មាននរណាមើលឃើញ និងគ្មាននរណាដឹងឮ អ្នកនយោបាយយួនផាំ-យ៉ាំងដុង ក៏ប្រកបដោយបញ្ញាញាណ ក៏បានសំរេចជោគជ័យ បាញ់ព្រួញមួយសម្លាប់បានសត្វស្លាបពីរ ៖ គឺបានបន្ថោកបន្ទាបពួកអាមេរិកាំង ព្រមទាំងវាតយកដែនដីកម្ពុជា ធ្វើជាទឹកដីរបស់យួន ។ ពិភពខាងលិច ប្រហែលជាមិនអាចដឹងជារឿងរហូតតទៅ អំពីអំពើពុតត្បុតដ៏សែនជ្រៅនៃជនអាស៊ីម្នាក់នេះ ។

«ទាំងនេះហើយ, លោកពុកធម៌, ប្រការដែលខ្ញុំបានរកឃើញ ដោយមានភស្តុតាងជាបង្អែក, ដោយគ្មានការស្អប់និងដោយគ្មានការស្រឡាញ់ ។ ខ្ញុំមិនបានដឹងទាំងអស់តែសោះ ពីមុននេះមក ថាសាធារណរដ្ឋជាទីស្រឡាញ់របស់ខ្ញុំ... បានត្រូវបង្កើតឡើងដោយសម្តេចសីហនុ និងលោកផាំ-យ៉ាំងដុងទៅវិញសោះ ។ ក្នុងករណីងាយស្រួលនឹងសម្លាប់ ។ គឺដើម្បីធ្វើប្រទេសកម្ពុជា ឲ្យទៅជាស្រុកដែលឥតមានខ្មែរ ឲ្យទៅជាសំបុកដែលឥតមានសត្វ !!

«ដោយស្មោះស្ម័គ្រជាទីបំផុត

សុទ្ធ-បូលិន» ។

❑

❑ ❑

## ខ្ញុំបានអានគម្ពីរទ្រឿង-មិញយ៉ាំង

ដោយបានរកឃើញ គំរោងសម្ងាត់របស់វៀតណាម ដើម្បីបំផ្លិចបំផ្លាញជនជាតិខ្មែរ មិនឲ្យមានសល់ពូជ, ឲ្យវិលត្រឡប់ទៅរកកាលសម័យព្រៃផ្សៃមុនពេលបារាំងមកដល់ ដែលលាក់បង្កប់នៅពីក្រោយព្រឹត្តិការណ៍១៨មីនា១៩៧០... ខ្ញុំក៏បានសំរេចធ្វើការសិក្សារជ្ជកាលព្រះម្ចាស់ក្សត្រិអង្គម៉ីឡើងវិញ (១៨៣៤-១៨៤១)... ហើយក៏បានរកឃើញគម្ពីររបស់ទ្រឿង-មិញយ៉ាំង នៅត្រង់ទំព័រ៤២៥, ៤២៦ និង៤២៧ (ទំព័រទាំងនេះ ខ្ញុំធ្លាប់បានអានរួចទៅហើយ តែពុំបានចាប់អារម្មណ៍) នៅក្នុងសៀវភៅ«ពង្សាវតានៃប្រទេសកម្ពុជា» របស់លោក Adhémard Leclère ដែលមានសេចក្តីដូចតទៅនេះ ៖

«ប្រជាជនខ្មែរដ៏អភ័ព្វនេះ ដែលហៀបតែនឹងដាច់ខ្យល់ស្លាប់ទៅហើយ នៅតែនឹកស្រណោះអាឡោះអាល័យ ទៅដល់ពូជស្តេចថែមទៀត (កកន ៖ ពេលនោះទ្រឿង-មិញយ៉ាំងដឹងថាជនជាតិខ្មែរស្រឡាញ់ស្តេចណាស់... ម្ល៉ោះហើយក៏រកមធ្យោបាយគ្រប់យ៉ាង ដើម្បីបំផ្លាញស្តេចខ្មែរឲ្យផុតពូជ) ។ ពូជស្តេចទាំងនេះ ធ្លាប់តែធ្វើទុក្ខបុកម្នេញជិះជាន់ប្រជារាស្ត្រខ្លួនឯង ជាយូរសតវត្សមកហើយ ដោយបង្កើត

សង្គ្រាមផ្ទៃក្នុង និងនាំសង្គ្រាមមកពីបរទេស (កកន ៖ ប្រការនេះ ធ្វើឲ្យយើងនឹក
ទៅដល់ស្តេចសីហនុ ដែលបាញ់ប្រហារពួកខ្មែរសេរី និងខ្មែរក្រហមតំណាលគ្នា...
ហើយរត់ទៅនាំសង្គ្រាមអាមេរិកាំង-យួន មកដុតបំផ្លាញប្រទេសរបស់ខ្លួនឯង...ទាំ
ងនេះជាលទ្ធផលស្នាដៃដ៏ឆ្នើមរបស់សម្តេចសីន-សាន ដែលជាទ្រឿង-មិញយ៉ាំង
សម័យទំនើប) ។ ពូជស្តេចទាំងនេះ គិតតែពីដណ្តើមអំណាចនិងរាជបល្ល័ង្ក ដណ្តើ
មខេត្តខ័ណ្ឌគ្នាទៅវិញទៅមកឥតត្រាប្រណី ដោយគ្មានអាណិតអាសូរដល់ប្រជាជន
ក្រីក្រអភ័ព្វ (កកន ៖ យើងអាចមើលឃើញស្តេចនរោត្តម-ចក្រពង្ស... ពេលដែល
បោះឆ្នោតចាញ់នរោត្តម-រណឫទ្ធិ សម័យអ៊ុនតាក់១៩៩៣ – ក៏បានដណ្តើមខេត្តខ្មែរ
នៅជំនាវខាងកើតនៃទន្លេមេគង្គ យកទៅប្រគល់ឲ្យយួន... នេះជាស្នាដៃត្រចះត្រចង់
របស់សម្តេចជា-ស៊ីម) ។ គឺអំពីពូជអំបូរស្តេចទាំងនេះហើយ ដែលប្រជាជនខ្មែរកំពុ
ងរង់ចាំជោគជតារបស់ខ្លួន ។ កាលនោះ គេរកមើលមិនឃើញ «អ្នកមានបុណ្យ» ទា
ល់តែសោះ, ពុំមានអ្នកមានបញ្ញា ឬអង្គពោធិសត្វណាម្នាក់ ដែលលេចឡើងផុស
ផ្លោ ដូចនៅប្រទេសចិន, អណ្ណាម, ភូមា, សៀម ដើម្បីកេណ្ឌប្រជារាស្ត្រទូទាំងនគរ
ឲ្យងើបឡើងគ្រងលើបល្ល័ង្ក ដែលដណ្តើមបានពីបរទេសមកវិញ ដោយកាន់អាវុធ
នៅដៃ នៅកណ្តាលចំណោមការស្រែកជ័យឃោស ដ៏ទ្រហឹងអ៊ឹងកងនៃប្រជាជាតិ
ទាំងមូល ។ ចៅហ្វាបែននិងមូ ប្រហែលជាអាចដើរតួជាវិរបុរសបានដែរ... ប៉ុន្តែពួក
អ្នកទាំងនេះពុំមែនជា «អ្នកមានបុណ្យ» ទេ គឺពុំមានវិរភាពខ្ពង់ខ្ពស់ ចិត្តក្លាហានអង់
អាចនោះឡើយ, ម៉្យាងទៀតពួកគេជាជនក្បត់ ដោយកាត់ទឹកដីបន្តវេនគ្នា ម្នាក់មួយ
ភាគម្នាក់មួយភាគ ច្រៀកចេញពីប្រទេសជាតិ យកទៅឲ្យសៀម ។ ម្ល៉ោះហើយប្រជា
ពលរដ្ឋដែលស្រវាំងភ្នែក ក៏បំភ្លេចសាវតារបស់ខ្លួនទាំងអស់ ដោយនឹកមមៃគិតតែ
ទៅលើក្រុមព្រះរាជវង្ស ដែលធ្លាប់តែគ្រប់គ្រងទៅលើពួកគេ តាំងពីមានការកកើត
ផែនដីមកម្ល៉េះ... ហើយពួកគេក៏ចាប់ផ្តើមសម្លឹងមើលទៅខេត្តបាត់ដំបង ដែលនៅទី
នោះ មានព្រះអង្គម្ចាស់ពីររូបគង់នៅ (ព្រះអង្គឯម និងអង្គឌួង) » ។

★★★ យោងតាមអត្ថបទខាងលើនេះ, ទ្រឿង-មិញយ៉ាំងដឹងច្បាស់ណាស់ ថា
ប្រជាជនខ្មែរត្រូវការស្តេចមានបុណ្យមួយអង្គ ដែលដណ្តើមឯករាជ្យពីជនបរទេស
ហើយ «គ្រប់គ្រងលើរាជសម្បត្តិ ដោយមានអាវុធនៅដៃ ក្រោមការស្រែកជ័យឃោ
សពីប្រជាជាតិទាំងមូល»...។ ត្រង់កន្លែងនេះ ខ្ញុំអាចមើលឃើញគោលបំណងរប-
ស់ពួកក្រុមភ្នាក់ងារយួននៅក្នុងព្រះរាជវាំងខ្មែរ (មានជាពិសេសសម្តេចសីន-សាន,
សម្តេចប៉ែន-នុត, សម្តេចជូឡុង) ដែលបានឆ្លាក់ឆ្លៃរូបស្តេចពាលា «នរោត្តម-សី
ហនុវរ្ម័ន» ឲ្យទៅជាអ្នកមានបុណ្យ...ទាមទារឯករាជ្យពីបារាំង ដោយសារកាំភ្លើង
ឈើ (តែជាឯករាជ្យដែលបាត់បង់ទឹកដីកម្ពុជាក្រោម) ។ «ខែវះឆ្លងផ្លូវ កូនកើតមុនឪ
ពរតាដើរលេង»... ស្តេចសីហនុជាព្រះបាទធម្មិក បានសោយរាជ្យមុនឪពុក ហើយ
ផ្តល់កិត្តិយសដល់ជីដូនជីតាថែមទៀត គឺពូជនរោត្តម ។ លោកសីន-សានបានពោ

លអំពីស្ដេចសីហនុថាជា ៖ «អ្នកតាអាចម៍ឆ្កែ... អ្នកតាអាចម៍ឆ្កែមានបារមីខ្លាំងពូកែណាស់»...។ ដូច្នេះលោកសឺន-សានបានយកអាចម៍ឆ្កែ មកសូន្យរូបជាស្ដេចមានបុណ្យ បណ្ដាលឲ្យប្រជារាស្ត្រខ្មែរដើរតាមផ្កាប់មុខ ស្លាប់អស់រាប់លាននាក់ ។

★★★ ដើម្បីឲ្យអ្នកផងជឿស្លុងថា ស្ដេចសីហនុជាអ្នកមានបុណ្យ, ភ្នាក់ងារយួនក្នុងព្រះរាជវាំង (រដ្ឋមន្ត្រីទី១យ៉ែម-សំបូរ) បានពិឃាតអ្នកចេះដឹងនិងអ្នកស្នេហាជាតិ ដែលហ៊ានរឹងទទឹងជាមួយស្ដេចសីហនុ មានជាអាទិទ្រង់ស៊ីសុវត្ថិ-យុត្តិវង្ស និងលោកអៀវ-កើស ។ តាំងពីថ្ងៃនោះមក ស្ដេចសីហនុជិះសេះលែងដៃ ៖ ចង់ដាក់រាជ្យ ហើយតោងទាមធ្វើស្ដេចវិញក៏បាន, ចង់លើកខ្លួនជាប្រមុខរដ្ឋជំនួសស្ដេចក៏បាន ចង់ជាន់ឈ្លីលើរដ្ឋធម្មនុញ្ញយ៉ាងដូចម្ដេចក៏បាន, ចង់ទាត់ជំនួយអាមេរិកាំងក៏បាន... ចង់អនុញ្ញាតឲ្យយៀកកុងមកតាំងនៅក្នុងទឹកដីខ្មែរក៏បាន... ដែលសុទ្ធសឹងជាទង្វើធ្វើឲ្យកម្ពុជាធ្លាក់ទន់ខ្សោយ ក្នុងប្រការបានចំណេញភោគផលទៅដល់ជនជាតិយួន ។ ទង្វើអស់ទាំងនេះ សុទ្ធសឹងតែល្មមសមរម្យនឹងភ្នែកខ្មែរទាំងអស់... ពីព្រោះព្រះអង្គជាអ្នកមានបុណ្យ ។ ដូច្នេះគោលបំណងរបស់ទ្រៀង-មិញយ៉ាំង (សឺន-សាន) គឺធ្វើឲ្យស្ដេចខ្មែរឆ្កួត ដើម្បីធ្វើឲ្យប្រជារាស្ត្រខ្មែរឆ្កួតមូរនប ស្របជាមួយគ្នានឹងស្ដេច ពោលឲ្យខ្លីទាំងស្ដេចទាំងរាស្ត្រ នាំគ្នារត់ចូលយៀកកុង ដូចសត្វមមៀចហើរចូលភ្លើង !! ។

❑

❑ ❑

នៅក្នុងអត្ថបទ Adhémard Leclère ដែលខ្ញុំចាត់ទុកថា ជាគម្ពីរទ្រៀង-មិញយ៉ាំង មានសរសេរបន្តទៀតថា ៖ «លោកឧត្ដមសេនិយអណ្ណាម អុង ទួងគុន (ទ្រៀងមិញយ៉ាំង) បានយល់ថា អ្វីៗដែលនៅសេសសល់ជាកម្លាំងថាមពលទាំងប៉ុន្មាននៅប្រទេសកម្ពុជា ពោលពួកក្រុមមនុស្សដែលមានសមត្ថភាព អាចប្រឆាំងទប់ទល់នឹងការគ្របសង្កត់របស់ជនជាតិយួន គឺត្រូវពឹងផ្អែកទៅលើក្រុមគ្រួសារស្ដេចនេះឯង (<u>កកន</u> ៖ ក្នុងសម័យទាមទារឯករាជ្យពីបារាំង, ពួកមានសមត្ថភាពសុទ្ធសឹងតែជាអ្នកជំនិតរបស់ក្រុមគ្រួសារស្ដេចសីហនុ... មានស៊ីសុវត្ថិ-យុត្តិវង្ស, សឹង-ង៉ុកថាន់, ស៊ឹម-វ៉ារ, អៀវ-កើស... ហេតុនេះហើយ បានជាពួកក្រុមមន្ត្រីយួន បានវាយក្រឡាខ្ទប់ពួកអ្នកទាំងនេះឲ្យវាំងស្ទះ ឥតមានច្រកចេញ) ។ អុង ទួងគុនក៏បានសំរេចរំលាយពួករាជវង្សឲ្យបាត់ស្រមោលពីលើផែនដីនេះ ដោយបង្កើតជម្លោះរវាងបងប្អូនស្ដេចទាំងពីរនាក់, អង្គឌួងនិងអង្គឯម, ដែលរហូតមកដល់ពេលនេះ ធ្លាប់តែត្រូវរ៉ូវគ្នារអ៊ូករអឺនឥតសៅហ្មង រួចហើយនិងឆ្លៀតឱកាសអំពីព្រឹត្តិការណ៍ផ្សេងៗ ដែលប្រាកដជានឹងកើតឡើងដោយសារជម្លោះនេះ ដើម្បីកំចាត់ចោលទាំងពីរនាក់ ក្នុងករណីដែលអ្នកទាំងពីរមិនបានកំចាត់គ្នាទៅវិញទៅមកនោះទេ (<u>កកន</u> ៖ ក្នុងសម័យស្ដេចសីហនុ គេបង្កើតជម្លោះរវាងម្ដាយនិងកូន... នៅពេលដែលព្រះករុណាសុរា-

ត្រិតសុគតទៅក្នុងឆ្នាំ១៩៦០, លោកសឺន-សាននិងលោកទីម-ង្វួន ជាអ្នកគាំទ្រព្រះមហាក្សត្រីយានីកុសុមៈឲ្យឡើងស្នងរាជ្យ... ចំណែកលោកអ៊ិន-តាំនិងលោកទឹម-ដុង ជាអ្នកគាំទ្រស្តេចសីហនុ តែងតាំងខ្លួនជាប្រមុខរដ្ឋ) ។

«អុងទួងគុន ក៏បានចាត់បញ្ជូនជនអណ្ណាមម្នាក់ ដែលក្លែងខ្លួនបន្លំជាខ្មែរឈ្មោះភគវា ឲ្យកាន់លិខិតមួយទៅថ្វាយព្រះឧបរាជអង្គឯម...។ ក្នុងលិខិតនោះបាននិយាយថា ដែលខ្លួន (អុង ទួងគុន) បានមកប្រទេសកម្ពុជា គឺដើម្បីមកផ្សះផ្សារបង្កើតសន្តិភាពនៅក្នុងព្រះរាជាណាចក្រតែប៉ុណ្ណោះ ដែលខ្លួនបានលើកព្រះម្ចាស់ក្សត្រីអង្គម៉ី ឲ្យឡើងគ្រងរាជ្យ គឺដោយព្រោះព្រះនាងគ្រាន់តែមានលក្ខណៈជា «ស្តេចបណ្តោះអាសន្ន» តែប៉ុណ្ណោះ សំរាប់រងចាំព្រះអង្គម្ចាស់ខ្មែរមួយអង្គ មានលទ្ធភាពមកកាន់កាប់ទឹកដី ។ នៅទីបំផុត អុង-ទួងគុននឹងរៀបចំជួយព្រះឧបរាជឲ្យឡើងគ្រងរាជសម្បត្តិ វាទាល់តែទ្រង់មានអ្នកប្រណាំងប្រជែងម្នាក់ នៅក្នុងរូបព្រះអនុជ គឺព្រះអង្គឌួង ដែលកំពុងតែឃុំបឃិត» ។

«ឧបរាជអង្គឯមក៏ជឿជាក់ថា ទ្រង់កំពុងតែមានភ័ព្វវាសនាឡើងវិញ, ប៉ុន្តែនៅពេលដែលគេទូលថា ទ្រង់មានអ្នកប្រជែងម្នាក់នៅក្នុងអង្គអានុជ ដែលប្រជារាស្ត្រកំពុងផ្តេកផ្តួលស្រឡាញ់ជាងទ្រង់, ព្រះឧបរាជក៏ថ្កោលទោសប្អូនរបស់ខ្លួនឯងមួយរំពេច ដោយផ្ញើលិខិតមួយច្បាប់ ទៅព្រះរាជាសៀមនៅបាងកក ។ នៅក្នុងចុតហ្មាយនោះ មានសេចក្តីថា ព្រះអង្គឌួងកំពុងតែឃុបឃិតក្បត់ផលប្រយោជន៍របស់សៀមនៅប្រទេសកម្ពុជា ។ ស្តេចសៀមក៏បញ្ជូនមន្ត្រីជាន់ខ្ពស់ពីររូប ទៅនាំខ្លួនព្រះអង្គឌួងមកទីក្រុងបាងកក ហើយហាមប្រាមទ្រង់មិនឲ្យវិលត្រឡប់ទៅមង្គលបូរីវិញទេ ។

«ដោយបានកំចាត់ប្អូនឲ្យខ្ចាតចេញឆ្ងាយរួចហើយ, ព្រះឧបរាជក៏ធ្វើដំណើរទៅខេត្តពោធិសាត់ជាមួយនឹងក្រុមគ្រួសាររបស់ទ្រង់ផ្ទាល់ និងជាមួយកូនព្រះអង្គឌួងផង ដែលទ្រង់នាំមកជាចំណាប់ខ្មាំង ព្រមទាំងជាមួយមន្ត្រីជាន់ខ្ពស់ជាច្រើនរូប ដែលទ្រង់ចាប់នាំមកពីខេត្តបាត់ដំបង, ដោយហេតុថា ពួកអ្នកទាំងនេះមានវិរភាពស្លុកស្លម្ភ មិនអាចទុកឲ្យនៅក្រោយខ្នងព្រះអង្គបានឡើយ ។

«លោកឧត្តមសេនិយអណ្ណាម (នៅខេត្តពោធិសាត់) ក៏បញ្ជាឲ្យចាប់ខ្លួនអ្នកទាំងអស់នេះ នៅពេលដែលពួកគេមកដល់ ហើយក៏បញ្ជូនទៅទីក្រុងភ្នំពេញ ។ ឧបរាជអង្គឯម មិនបានយល់ពីព្រឹត្តិការណ៍ដែលទើបកើតឡើងនេះទេ ពីព្រោះរូបទ្រង់បានត្រូវនាយទាហានយួន ដែលបញ្ជាទ័ពនៅខេត្តពោធិសាត់ទទួលស្វាគមន៍យ៉ាងអធិកអធម ។ ទ្រង់បន្តដំណើរទៅទីក្រុងភ្នំពេញ ដោយមានកងល្បាតយួនហែរហាមទំនងដូចជាផ្តល់កិត្តិយស ។ ជាដំបូងទ្រង់បានទទួលស្វាគមន៍យ៉ាងគគ្រឹកគគ្រេងដោយឧត្តមសេនិយ អុង ទួងគុន ជាមួយនិងប្រជានុរាស្ត្រ ដែលនឹកស្មានថា ស្តេចមករំដោះពួកខ្លួន ក៏នាំគ្នាស្រែកជ័យឃោសយ៉ាងទ្រហឹងអ៊ឹងអាប់ ។ ក៏ប៉ុន្តែនៅពេលរាត្រីធ្លាក់មកដល់ ឧត្តមសេនិយអណ្ណាម អុង ទួងគុន ដែលមានការទាស់ចិត្តយ៉ាង

ខ្លាំង ក្នុងប្រការដែលប្រជានុរាស្ត្រ បានមកទទួលព្រះអង្គម្ចាស់ដោយកុះករ ក៏បាន បញ្ជាឲ្យគេចាប់ព្រះអង្គឯម ដាក់ក្នុងទ្រុងដែក ហើយនៅពេលព្រឹកឡើង នាំយកទៅ ក្រុងវេ (១៨៤០) ។

«ចំណែកពួកមន្ត្រីជាន់ខ្ពស់ ដែលនាំខ្លួនមកពីទីក្រុងបាត់ដំបង... ជាច្រើនគ្នា ណាស់ បានត្រូវយកទៅប្រហារជីវិត ដោយឥតមានជំនុំជំរះ ។ អ្នកនៅសេសសល់ ទាំងប៉ុន្មាន ត្រូវនាំយកទៅដាក់គុកនៅទីក្រុងវេ ។

«នៅឯក្រុងបាងកកឯណោះ, ព្រះអង្គឌួងដែលត្រូវចោទថា បានឃុបឃិតជាមួ យនិងបងប្រុសរបស់ខ្លួនឯង... ត្រូវបានគេចាប់ដាក់ខ្នោះ ហើយឃុំឃាំងទុកក្នុង ព្រះរាជវាំងស្តេចសៀម» ។

★★★ យោងតាមអត្ថបទខាងលើ យើងអាចមើលឃើញថា គ្រាន់តែរឿងទ្រឿ ង-មិញឃុំាំងបញ្ជូនជនអណ្ណាមម្នាក់បន្លំធ្វើខ្មែរឈ្មោះ ភគវ៉ា ទៅជួបព្រះអង្គឯម... យួនក៏អាចបង់សំណាញ់មរណៈ ចាប់មន្ត្រីខ្មែរទាំងជង់ យកទៅប្រហារជីវិត ។ ត្រង់ ចំណុច ភគវ៉ា នេះ ខ្ញុំបានសម្លឹងឃើញជនជាតិយួនម្នាក់ឈ្មោះ សឺន-សាន ដែល បន្លំខ្លួនជាខ្មែរក្រោមចូលមកក្នុងប្រទេសកម្ពុជា... ហើយក៏បានធ្វើឲ្យព្រះរាជវាំងខ្មែរ ក្រឡាប់ចាក់ ។ សឺន-សានជាមេការទូតយួនជាន់ខ្ពស់បំផុត (ពីព្រោះឈ្មោះគាត់សឺ ន-សាន មានន័យថាភ្នំថៃសាន, ភ្នំដែលមានកំពូលខ្ពស់បំផុតនៅប្រទេសចិន)...ប្រ ហែលជាខ្ពស់ជាងផាំ-យ៉ាំងដុងទៀតផង ដែលអុងហូបានបញ្ជូនមកដើម្បីសម្លាប់ ជនជាតិខ្មែរ ។ គ្រាន់តែសឺន-សានចូលមកក្នុងសៃរៀននៃគណបក្សប្រជាធិបតេ- យ្យកាលណា... ស្រាប់តែគេឃើញមានឃាតកម្មចម្លែកៗ ដែលគេរកមុខរកបាតមិ នឃើញ... គឺការបំពុលទ្រង់ស៊ីសុវត្ថិ-យុត្តិវង្ស ហើយទម្លាក់ទោសកំហុសទៅលើ បារាំង, ការបោះគ្រាប់បែកដៃទៅលើរូបលោកអៀវ-កើស ហើយទម្លាក់ទោសកំហុ សទៅលើព្រះក្សត្រីកុសុមៈ (ដោយកាលនោះ ព្រះក្សត្រីជាសាហាយស្មន់ជាមួយនឹ ងលោកយ៉ែម-សំបូរ... ដូចតែព្រះម្ចាស់ក្សត្រីអង្គម៉ី ជាសាហាយស្មន់ជាមួយទ្រឿង មិញយ៉ាំង) ។ ការពិឃាតលោក រ៉េស៊ីដង់ ស៊្យូប៉េរីយើរ Jean De Raymond ដោយ វាយក្បាលនឹងញញួរ (ពីសំណាក់យួនឃៀកមិញ) ហើយបែរជាទម្លាក់កំហុសទៅ លើបក្សពួកលោកសឺង-ង៉ុកថាន់ ។ តាមពិតលោកសឺន-សាន ជាភេរវករជាន់ខ្ពស់ បំផុត ដែលកកូរពិភពនយោបាយកម្ពុជា បង្កើតចលាចលក្នុងគោលប្រាថ្នា ឲ្យមតិ មហាជនខ្មែរបំភ្លេចផលប្រយោជន៍នៃកម្ពុជាក្រោមតែប៉ុណ្ណោះ ។

★★★ នៅថ្ងៃទី៣១សីហា១៩៥៩, មានគ្រាប់បែកមួយផ្ទុះនៅក្នុងព្រះរាជវាំងកម្ពុ ជា បណ្តាលឲ្យស្លាប់អ្នកបំរើវាំងមួយចំនួន និងនាយពិធីការឈ្មោះ នរោត្តម-វ៉ាគ្រី វ៉ាន់ ។ នៅពេលនោះ ក៏មានវត្តមានរបស់ឯកឧត្តមសឺន-សានផងដែរ ដែលបានមក ដល់ព្រះរាជវាំងទាន់ពេលវេលា ដើម្បីស្រោចស្រង់ជីវិតដល់ព្រះមហាក្សត្រខ្មែរ គឺ ព្រះនរោត្តម-សុរាម្រិត និងព្រះមហាក្សត្រីយានីសុសុមៈ ។ ត្រង់កន្លែងនេះហើយ

ដែលខ្ញុំចាប់ផ្ដាក់បាន ថាលោកសឺន-សានជាទ្រឿង-មិញយ៉ាំង... ពីព្រោះតាមក្បួនចិន ជនណាដែលមានវត្ថុមាននៅកន្លែងកើតហេតុ ដែលបណ្ដាលឲ្យក្រឡាប់ចាក់ព្រះរាជនគរ ជននោះហើយជាអ្នកត្រួតត្រាពិភពគុន ។ លោកសឺន-សានបានដឹងជាមុនថា ស្ដេចសីហនុមានបំណងសម្លាប់ឪពុកម្ដាយខ្លួនឯង ដើម្បីឆ្លៀតឱកាសនៃការវឹកវរក្នុងព្រះរាជវាំង ឡើងគ្រងរាជសម្បត្តិជាមួយអ្នកម្នាងម៉ូនិក ។ ដូច្នេះលោកសឺនសានមិនបានមកជួយស្រោចស្រង់មហាក្សត្រខ្មែរនោះទេ... តែមកបង្កើតការវិវាទស្លាប់រស់ រវាងស្ដេចម៉ែនិងស្ដេចកូនទៅវិញ ។ ដោយទុកព្រះមហាក្សត្រីយានីកុសុមៈឲ្យនៅរស់... សឺន-សានក៏ធ្វើឲ្យម្ចាស់ក្សត្រីអង្គនេះ ក្លាយទៅជាឧបសគ្គបិតនៅកណ្ដាលផ្លូវនៃមហិច្ឆិតារបស់ស្ដេចសីហនុ ដែលចង់គ្រប់គ្រងរាជសម្បត្តិឡើងវិញ ដែលជាហេតុនាំទៅរកព្រឹត្តិការណ៍នៃថ្ងៃ១៨មីនា១៩៧០ ។ ម្យ៉ាងវិញទៀត ដោយបណ្ដោយឲ្យមានការផ្ទុះគ្រាប់បែបនៅព្រះរាជវាំងកម្ពុជា... លោកសឺន-សានកំពុងតែរៀបចំនយោបាយក្រៅប្រទេសនៃកម្ពុជា ឲ្យរត់ទៅបុកទង្គិចពេញទំហឹងជាមួយនឹងសហរដ្ឋអាមេរិក និងក្រុមបក្សសេអាតូ ហើយក៏កំពុងរុញច្រានស្ដេចសីហនុឲ្យធ្លាក់ចូលទៅក្នុងកណ្ដាប់ដៃប្រទេសចិនផងដែរ ។

★★★ នៅខែមករា១៩៦៩... លោកសឺន-សាន ក្នុងនាមជារដ្ឋមន្ត្រីទី១ខ្មែរ បានចុះហត្ថលេខាជាមួយនឹងអ្នកតំណាងនៃសហរដ្ឋអាមេរិក លោក Chester Bowles លើសន្ធិសញ្ញាដែលអនុញ្ញាត ឲ្យទាហានអាមេរិកាំងចូលធ្វើអន្តរាគមន៍ ដេញតាមចាប់យៀកកុងនៅក្នុងទឹកដីកម្ពុជា ។ ដូច្នេះគឺលោកសឺន-សាននេះហើយ ដែលជាអ្នករៀបចំបំផ្ទុះប្រទេសកម្ពុជា ដែលជា«កោះសន្តិភាពបិតនៅកណ្ដាលឃ្លាំងរំសេវ»នៃសង្គ្រាមអាមេរិកាំង-វៀតណាម ។ គឺលោកសឺន-សាននេះហើយ ដែលបានរៀបចំឲ្យលោក Kissinger ទម្លាក់គ្រាប់បែកទៅលើកម្ពុជាក្នុងឆ្នាំ១៩៦៩... ជំរុញឲ្យយួនយៀកកុងចូលទៅស៊ីរូង ដល់កណ្ដាលថ្លើមប្រមាត់នៃប្រទេសកម្ពុជា និងជំរុញឲ្យប្រជារាស្ត្រខ្មែររត់ចូលជ្រុំប៉ុល-ពតយ៉ាងសស្រាក់សស្រាំ ។ នៅទីបំផុត គឺលោកសឺន-សាននេះហើយ ដោយសហការជាមួយផាំ-យ៉ាំងដុង ដោយយកស្ដេចសីហនុជាទីងមោងសំរាប់ទាញខ្សែសំណាញ់មរណៈ សំរាប់លប់លើប្រជាជនខ្មែរទាំងមូល ដែលបង្កើតឲ្យមានព្រឹត្តិការណ៍នៃថ្ងៃ១៨មីនា១៩៧០ ព្រមទាំងនាំទៅរកជោគជ័យកុម្មុយនិស្តដោយចៀសមិនរួច នៅថ្ងៃទី១៧មេសា១៩៧៥ ។៚

❑ ❑

❑